# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៩៣១ អក
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

**សាលក្រមព្រហ្មទណ្ឌ**
លេខ ៨៣ "ង១"
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៣១ អ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្ដាល និងមានទីលំនៅបច្ចុប្បន្នភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] វ៉េង (រស់) ម្ដាយឈ្មោះ [redacted] សុខ(រស់) ប្រពន្ធឈ្មោះ [redacted] ស្រីល័ក្ខ មានកូនចំនួន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។(ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចផ្ទះជួលភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ដែលមានលោកមេធាវី [redacted] និងលោកមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធារី។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៨ និង ៣០នាទីស្ថិតនៅចំណុចផ្ទះជួល ក្នុងភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ជនត្រូវចោទឈ្មោះ [redacted] សុធារី បានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះឈ្មោះ [redacted] សុខា និងបានប្រតាយប្រតប់គ្នា។ បន្ទាប់មកជនត្រូវចោទឈ្មោះ [redacted] សុធារី បានរត់ទៅយកកន្ត្រៃចាក់ចំក្បាលជនរងគ្រោះ បណ្ដាលឱ្យរបួសរយៈហូរឈាម ដេរចំនួន ០៦ថ្នេរ ខណៈពេលនោះជនរងគ្រោះក៏បានធាក់ជនត្រូវចោទបណ្ដាលឱ្យដួលម៉ូតូតែម្ដង។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥៤ ដកសស ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៧ ដកសព ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។



Scanned with CamScanner

-បានឃើញ ដីកាដំណោះស្រាយលេខ ៥៦១ ដកដស ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៦១ ដកចត ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

## នាពេលសវនាការ

១- ជនជាប់ចោទឈ្មោះ [redacted] សុធារី បានឆ្លើយថា៖ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៧យប់ជាងខ្លួនបានទៅផ្ទះជួល ដើម្បីរកមិត្តភក្តិ ។ ពេលទៅដល់ ខ្លួនបានហៅមិត្តភក្តិរបស់ខ្លួនទៅផ្ទះវិញ ។ ពេលទៅរកមិត្តភក្តិខ្លួនបានផឹកស្រាសាច់ជុំស្រវឹងបន្តិច។ បន្ទាប់មកឈ្មោះ [redacted] សុខា បានឃាត់ហើយច្រានខ្លួនហើយក៏មានការប្រតាយប្រតបគ្នាទៅវិញទៅមក។ ឈ្មោះ [redacted] សុខា បានវាយខ្លួនត្រូវចំក្បាលចំនួន ០៣ដៃបន្ទាប់មកខ្លួនក៏ស្រវាបានកន្ត្រៃយកមកក្រវីបណ្ដាលឱ្យត្រូវចំក្បាលរបស់ឈ្មោះ [redacted] សុខា នោះចេញឈាម ។ ចំណែកខ្លួនត្រូវបានឈ្មោះ [redacted] សុខា នេះវាយឡើងប៉ោងក្បាលដែរ ។ ខ្លួនពុំមានបំណងយកកន្ត្រៃទៅចាក់ឈ្មោះ សុខា នោះទេ យកដើម្បីការពារខ្លួនឈ្មោះ សុខា បានវាយខ្លួនដោយពុំដឹងហេតុផល។ ពេលឈ្មោះ សុខា នោះវាយខ្លួន គឺវាបានផឹកស្រាឡើងស្រវឹងហើយ ក្រោយកើតហេតុខ្លួនបានជិះម៉ូតូចេញហើយឈ្មោះ សុខា បានធាក់ម៉ូតូខ្លួនដួលហើយត្រូវរបួសហូរឈាមបន្ទាប់មកសមត្ថកិច្ចក៏បានឃាត់ខ្លួនរូបខ្លួន និងឈ្មោះ [redacted] សុខា។ នៅដំណាក់កាលសមត្ថកិច្ចខ្លួនបានសម្រេចសម្រមសម្រួលគ្នាអស់ហើយ ។ ដោយឈ្មោះ ង៉ាក់ សុខា នេះបានដកពាក្យបណ្ដឹងឈប់ប្ដឹង និងមិនទាមទារសំណងនោះទេ ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា ភេទប្រុស បានឆ្លើយថា:កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២១ វេលាម៉ោងប្រហែល ០៥ល្ងាចខ្ញុំបាទ និងឈ្មោះ តាក់ ត្រូវជាមិត្តភក្តិរបស់ខ្លួនបាននាំគ្នាបាននាំគ្នាលេងឈូសហើយក៏បំបែកគ្នាឈប់លេងអស់ទៅ។ លុះដល់វេលាម៉ោងប្រហែល ០៨យប់នាថ្ងៃដដែល ខ្លួនក៏បានជួបឈ្មោះ តាក់ នៅមុខបន្ទប់ជួលភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ពេលនោះខ្លួនក៏បានស្រែកហៅមិត្តភក្តិតែឈ្មោះ តាក់ បានឆ្លើយជំនូស ក៏បានទាស់សម្ដីគ្នា ហើយក៏បានប្រតាយប្រតប់គ្នា បន្ទាប់មកឈ្មោះ តាក់ ក៏រត់ទៅយកកូនកន្ត្រៃចាក់ខ្លួនចំក្បាលបណ្ដាលឱ្យមានរបួសតែម្ដង ។

៣- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាបានយកកន្ត្រៃចាក់ចំក្បាលរបស់ជនរងគ្រោះបណ្ដាលឱ្យរបួសចេញឈាម ប្រាកដមែន ដែលច្បាប់បានកំណត់អំពើដែលប្រព្រឹត្តនៅចំណុចផ្ទះជួលស្ថិតនៅភូមិព្រែតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## យល់ឃើញថា

**ក/ អំពីពិរុទ្ធភាព**

១- តាមដីកាដំណោះស្រាយលេខ ៥៦១ ដកដស ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល បញ្ជូនមកជំនុំជម្រះពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅចំណុចផ្ទះជួលស្ថិតក្នុងភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុធារី បង្ហាញឱ្យឃើញថា៖ ខ្លួនពិតជាបានយកកន្ត្រៃក្រវី ហើយត្រូវចំក្បាលជនរងគ្រោះបណ្ដាលឱ្យបែកចេញឈាមពិតប្រាកដមែន ។

៣-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា បង្ហាញឱ្យឃើញថា:ខ្លួនពិតជាត្រូវបានជនត្រូវចោទយកកន្ត្រៃចាក់ចំក្បាលបណ្ដាលឱ្យរងរបួសចេញឈាមប្រាកដមែន ។

៣- តាមរបាយការណ៍សរុបលេខ ១៨៣ របក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ បានធ្វើសេចក្តីសន្និដ្ឋានថា:ជនសង្ស័យឈ្មោះ [redacted] សុធារី ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិសង្កាត់កើតហេតុ មុខរបរកម្មករសំណង់ ពិតជាបានធ្វើសកម្មភាពប្រតាយប្រតប់ជាមួយជនរងគ្រោះបណ្ដាលឲ្យមានរបួសស្នាមទាំងសងខាង បន្ទាប់មកជនសង្ស័យបានរត់ទៅយកកន្ត្រៃចាក់លើជនរងគ្រោះចំក្បាលបណ្ដាលឲ្យមានរបួសស្នាមដេរ៦ថ្នេរ ទើបជនរងគ្រោះបានហក់ធាក់និងវាយជាច្រើនដៃទៅលើជនសង្ស័យបណ្ដាលឲ្យមានរបួសស្នាមដូចគ្នា កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៨ និង ៣០នាទីនៅចំណុចផ្ទះជួលផ្លូវភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រាកដមែន ។

៤- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបង្ហាញឱ្យឃើញថា ៖ តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាបានយកកន្ត្រៃចាក់លើជនរងគ្រោះចំក្បាលបណ្ដាលឲ្យមានរយះចេញឈាមដេរចំនួន ៦ថ្នេរប្រាកដមែន។

៥- តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ ចម្លើយជនជាប់ចោទ តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានតំណាងអយ្យការ ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាបានយកកន្ត្រៃចាក់ទៅលើជនរងគ្រោះបណ្ដាលឱ្យរយះចេញឈាមដេរអស់ចំនួន ៦ថ្នេរ ប្រាកដមែន ដែលអំពើដែលបានប្រព្រឹត្តនៅចំណុចផ្ទះជួលភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ ត្រូវច្បាប់បញ្ញត្តិថាជាបទ: **ហិង្សាដោយចេតនា** តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

៦- ជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ ជានីតិជន មានស្មារតី និងសមត្ថភាព យល់ដឹងគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់នូវអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដ ក្នុងការប្រព្រឹត្តអំពើដូចមានក្នុងបទចោទប្រកាន់ ។



Scanned with CamScanner

៧- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយល្អរបស់សង្គម ពិសេសប៉ះពាល់ដល់រូបរាងកាយ ដែលច្បាប់បានហាមឃាត់ ។

៨- មានធាតុផ្សំនៃបទល្មើស និងភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ (អត្តសញ្ញាណខាងលើ) ពីបទ: ហិង្សាដោយចេតនា ទៅលើអំពើដែលប្រព្រឹត្តនៅចំណុចផ្ទះជួល ភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ តាមកំណត់ច្បាប់ ។

**ខ/ អំពីវត្ថុចាប់យក**

- គ្មាន ។

**<u>ហេតុដូច្នេះសម្រេច</u>**

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ ប៉ុន្តែទោសនេះព្យួរតាមមាត្រា ១០៦,មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅចំណុចផ្ទះជួល ភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុធារី ហៅតាក់ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **តំណាងអយ្យការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១០កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កណ្តាល,ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner